សំរាប់ការកើតមុន (ដែលជាការព្យាបាលសាមញ្ញមួយកាលពីមុំជំនាន់ឆ្នាំ១៩៦០) អាចច្រើនមានគ្រោះថ្នាក់កើតជម្ងឺមហារីកគ្រន្ថី "ថាយរ៉យ្ត"។

ជម្ងឺមហារីកគ្រន្ថី "ថាយរ៉យ្ត" អាចកើតឡើងដល់ជនគ្រប់វ័យទាំងអស់។ តែចំពោះអ្នកណាដែលគ្រួសារមានបញ្ហាគ្រន្ថី "ថាយរ៉យ្ត" គ្រោះថ្នាក់នៃការមានបញ្ហាដូចគ្នានេះក៏កើនឡើងដែរ។ ប្រជាជនដែលកើតនៅអាស៊ីប៉ែកអគ្នេយ៍ និងប្រទេសអឺរុបនានានៅ Middle East អាចច្រើនមានបញ្ហាគ្រន្ថី "ថាយរ៉យ្ត" ពីព្រោះការបរិភោគចំណីអាហារនៃប្រទេសនោះខ្វះជាតិ iodine។ យ៉ាងណាមិញ គ្រោះថ្នាក់នេះក៏ចុះអន់ថយដែរពេលមកនៅប្រទេសអូស្ត្រាលី។

ទោះបីការប្រើអំបិលម្យ៉ាងដែលមានជាតិ iodine (iodised salt) អាចជួយការពារកុំឲ្យមានបញ្ហាគ្រន្ថី "ថាយរ៉យ្ត"ក្តី ការញ៉ាំថ្នាំ iodine tablets ឬ kelp tablets អាចធ្វើឲ្យបញ្ហានេះមានសភាពកាន់តែធ្ងន់ធ្ងរ។ ជនណាដែលសង្ស័យថាខ្លួនមានបញ្ហាគ្រន្ថី "ថាយរ៉យ្ត" ត្រូវទៅជួបវេជ្ជបណ្ឌិតរបស់ខ្លួន។

ចំពោះពត៌មានបន្ថែមទៀតសូមអ្នកទាក់ទងទៅក្រុមជួយឧបត្ថម្ភមាន the Australian Thyroid Foundation, PO Box 186, Westmead NSW 2145, ទូរស័ព្ទ (02) 9890 6962 ឬ Thyroid Australia, PO Box 2575, Fitzroy Delivery Centre, VIC 3065, ទូរស័ព្ទ (03) 9561 2483។

បើអ្នកមានការពិបាកក្នុងការទូរស័ព្ទជាភាសាអង់គ្លេស សុំអ្នកទាក់ទងទៅផ្នែកផ្តល់អ្នកបកប្រែ Translating and Interpreting Service (អក្សរកាត់ **TIS**) លេខ 131 450។

អ្នកអាចយកពត៌មានផ្នែកសុខភាពបន្ថែមទៀតជាភាសាខ្មែរ ពីកំព្យូទ័រតាមរយៈ
**Multicultural Communication website at http://mhcs.health.nsw.gov.au**

NSW Multicultural Health Communication Service
website: http://mhcs.health.nsw.gov.au
e-mail: mhcs@sesahs.nsw.gov.au
phone: (02) 9382 8111

multicultural communication

KHMER
8th November 1999

# តើបញ្ហាគ្រន្ថី "ថាយរ៉យ្ត" អាចមានឥទ្ធិពលដល់សុខភាពរបស់អ្នកតាមរបៀបណា ?

# How thyroid problems can affect your health

NSW HEALTH
DEPARTMENT

# តើបញ្ហាគ្រន្ថី "ថាយរ៉យ្ដ" អាចមានឥទ្ធិពលដល់សុខភាពរបស់អ្នកតាមរបៀបណា ?

# How thyroid problems can affect your health

នៅពេលដែលស្ត្រីម្នាក់ឈ្មោះ ហៀង បានត្អូញត្អែរជាលើកដំបូងប្រាប់វេជ្ជបណ្ឌិតគាត់ ពីការដែលគាត់ចេះតែហត់ មានការកើតទុក្ខធ្លាក់ទឹកចិត្តខ្លាំង និងការឡើងទម្ងន់ វេជ្ជបណ្ឌិតគាត់បានស្នើរឲ្យគាត់ធ្វើការហាត់ប្រាណបន្ថែមទៀត។ ប៉ុន្តែនៅពេលដែលបញ្ហានោះចេះតែនៅមានទៀត វេជ្ជបណ្ឌិតក៏បានបញ្ជូនគាត់ទៅពេទ្យវិកលចរិត។ ក៏ប៉ុន្តែទាល់តែក្រោយមកទើបគេបានពិនិត្យដឹងថា ហៀង មិនមានការកើតទុក្ខធ្លាក់ទឹកចិត្តខ្លាំងទេ គឺគាត់មានបញ្ហាបដែលណ្ដាលមកពីគ្រន្ថី "ថាយរ៉យ្ដ" (thyroid gland) - ដែលជាគ្រន្ថីម្យ៉ាងរាងដូចមេអំបៅ ឋិតនៅក្រោម " ផ្នែកប៉ោងបំពងក " (Adam's apple)។

មនុស្សភាគច្រើនមិនដឹងថាគ្រន្ថី "ថាយរ៉យ្ដ"ជាអ្វីទេ ហើយក៏មិនដឹងនូវមុខងាររបស់គ្រន្ថីនេះដែរ។ យ៉ាងណាមិញគ្រន្ថី "ថាយរ៉យ្ដ" មានឥទ្ធិពលដល់ផ្នែកជាច្រើននៃសរីរាង្គកាយ ហើយអាចធ្វើឲ្យមានរោគសញ្ញាជាច្រើនផង។ នៅក្នុងករណីរបស់ហៀង រោគសញ្ញាទាំងនេះ ជួនកាលអាចធ្វើឲ្យច្រឡំទៅនិងបញ្ហាឯទៀតដូចជាការកើតទុក្ខធ្លាក់ទុក្ខចិត្តខ្លាំង ការធ្វើការច្រើនពេក ឬដោយសារមកពីការចូលវ័យកាន់តែចាស់។ បញ្ហាគ្រន្ថី "ថាយរ៉យ្ដ" ជាបញ្ហាសាមញ្ញមួយ ដែលកើតឡើងដល់ម្នាក់ក្នុងចំណោមមនុស្ស២០នាក់។ បញ្ហានេះច្រើនកើតឡើងដល់ស្ត្រី ពោលគឺមានស្ត្រីម្នាក់ក្នុងចំណោមស្ត្រី១៨នាក់មានបញ្ហាគ្រន្ថី "ថាយរ៉យ្ដ"នៅពេលណាមួយក្នុងឆាកជីវិត ជាពិសេសអាយុម្ភៃ២០ ទៅ៣០ ហើយនិងអាយុពី៦០ឡើងទៅ។

ទោះបីវាមិនបណ្ដាលឲ្យបាត់បង់ជីវិតក្ដី តែបញ្ហាគ្រន្ថី "ថាយរ៉យ្ដ"នេះអាចបណ្ដាលឲ្យមានឥទ្ធិពលដល់សុខុមាលភាព។ វាអាចមានឥទ្ធិពលដល់អារម្មណ៍ កំរិតថាមពល ការអត់ធ្មត់ និងធាតុត្រជាក់ឬក្ដៅ ហើយចំពោះស្ត្រីអាចមានឥទ្ធិពលដល់ការធ្លាក់រដូវនិងភាពមានកូនឬអត់។

បញ្ហារបស់ហៀង គឺបណ្ដាលមកពីគ្រន្ថី "ថាយរ៉យ្ដ" (thyroid) បង្កើតអ័រម៉ូន (hormone)តិចពេក ដែលធ្វើឲ្យរាងកាយមានសភាពយឺត។ ជារឿយៗរោគសញ្ញាមានដូចជា ការចេះតែហត់ ងងុយ និងការចុះទម្ងន់៣-៤ គីឡូដោយគ្មានហេតុផល។ ក្រៅពីនេះរោគសញ្ញឯទៀតដែលអាចមាន ដូចជាការចេះតែភ្លេចភ្លាំង ការពិបាកក្នុងការផ្ចង់គំនិត សក់ឡើងគ្រើមហើយស្ងួត ការជ្រុះសក់ ការជ្រុះចញ្ចើម ស្បែកឡើងស្ងួត ធ្លាក់ឈាមរដូវច្រើន ក្រចកស្រួយ ការទល់លាមក និងការឆាប់រងា។

ចំណែកអ្នកខ្លះវិញ គ្រន្ថី "ថាយរ៉យ្ដ" បញ្ចេញអ័រម៉ូន (hormone)ច្រើនពេក ដែលធ្វើឲ្យរាងកាយមានសភាពលឿន ជាហេតុធ្វើឲ្យចុះទម្ងន់ ហើយនិងបេះដូងដើរញាប់។ រោគសញ្ញផ្សេងទៀតមានដូចជាមានអារម្មណ៍ថាក្ដៅ បែកញើស ឆាប់ភ័យឬធុញថប់ដំណើរគេងមិនលក់ ភ្នែកឡើងប៉ោង ការសម្លឹងមើលមិនព្រិចភ្នែក។ លក្ខណៈទាំងពីរបែបនេះគេអាចពិនិត្យដឹងបានដោយការពិនិត្យមើលឈាម ហើយភាគច្រើនការព្យាបាលនឹងធ្វើឲ្យជននោះមានអារម្មណ៍ នឹងមានភាពជាធម្មតាឡើងវិញ។

ការផ្លាស់ប្ដូរដែលអាចកើតឡើង គឺថាគ្រន្ថី "ថាយរ៉យ្ដ" នេះអាចរីកធំ - ក៏ប៉ុន្តែវាមិនមែនចេះតែបណ្ដាលឲ្យខូចសុខភាពទេ។ ជួនកាលមានដុំម្យ៉ាងដុះនៅលើគ្រន្ថី "ថាយរ៉យ្ដ" ដែលគេហៅថា nodules។ តាមធម្មតាវាច្រើនតែមិនមែនជាជម្ងឺមហារីកឡើយ។ វាជាការសំខាន់ដែលត្រូវឲ្យវេជ្ជបណ្ឌិតពិនិត្យមើលដោយការវះកាត់តូចមួយ (biopsy) (ដើម្បីយកកោសិកា cells ដុំនោះទៅពិនិត្យមើល) សំរាប់បញ្ជាក់ឲ្យដឹងច្បាស់លាស់។ ជម្ងឺមហារីកគ្រន្ថី "ថាយរ៉យ្ដ" អាចកើតឡើងដល់ជនគ្រប់វ័យទាំងអស់ ហើយគេអាចព្យាបាលបានជោគជ័យបើកាលណាឆាប់ពិនិត្យដឹង។ ជនណាដែលធ្លាប់បានទទួលការព្យាបាលតាមវិទ្យុសកម្ម radiotherapy for acne

លេខទូរស័ព្ទទាំងនេះត្រឹមត្រូវនៅពេលបោះពុម្ព ក៏ប៉ុន្តែអាចមិនបានកែតម្រូវតាមការលៈទេសៈ។ លោក-អ្នក ប្រហែ អាចត្រូវមើលបញ្ជាក់លេខនៅក្នុង"សៀវភៅទូរស័ព្ទ" (Telephone Directory)។

REVIEWED May 2001
NSW Multicultural Health Communication Service